ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងយុត្តិធម៌

លេខ : ១3 កយ.សសរ/២១

# សេចក្តីសម្រេច
## ស្តីពី
## សមាសភាព និង ការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈកម្មការជាតិដោះលែងដោយមានលក្ខខណ្ឌ

## រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើក្រមនីតិវិធីព្រហ្មទណ្ឌ
- បានឃើញអនុក្រឹត្យលេខ ២៤០ អនក្រ.បក ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងយុត្តិធម៌
- បានឃើញប្រកាសលេខ ០៩០ កយ.ប្រក ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២១ ស្តីពីបែបបទនៃការឃ្លាំមើលតាមដាន ការត្រួតពិនិត្យ និងការបញ្ចូលទៅក្នុងសង្គមវិញនៃទណ្ឌិតដែលត្រូវបានដោះលែងដោយមានលក្ខខណ្ឌ
- យោងលិខិតលេខ១៥៤០ សជណ ចុះថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០២១ របស់ក្រសួងមហាផ្ទៃ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងយុត្តិធម៌

## សម្រេច

**ប្រការ១ ..**

សេចក្តីសម្រេចនេះ កំណត់អំពីសមាសភាព និង ការរៀបចំនិងការប្រព្រឹត្តទៅរបស់គណៈកម្មការជាតិដោះលែងដោយមានលក្ខខណ្ឌ។

គណៈកម្មការជាតិដោះលែងដោយមានលក្ខខណ្ឌ សរសេរជាអក្សរកាត់ថា "**គ.ជ.ល.**" មានសមាសភាពដូចខាងក្រោម៖

| | | | |
|---|---|---|---|
| ១- ឯកឧត្តម | **គីម សន្តិភាព** | រដ្ឋលេខាធិការក្រសួងយុត្តិធម៌ | ប្រធាន |
| ២- ឯកឧត្តម | **ប៉ាច ហមផាន** | រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | អនុប្រធាន |
| ៣- ឯកឧត្តម | **ឃឹម សារី** | អនុរដ្ឋលេខាធិការក្រសួងយុត្តិធម៌ | អនុប្រធាន |
| ៤- ឯកឧត្តម | **ម៉ែន ពេជ្រសាលី** | អគ្គនាយកនៃអគ្គនាយកដ្ឋានកិច្ចការអយ្យការ និងព្រហ្មទណ្ឌ នៃក្រសួងយុត្តិធម៌ | សមាជិក |
| ៥- ឯកឧត្តម | **នែម សាខុធ** | អគ្គនាយកនៃអគ្គនាយកដ្ឋាន ពន្ធនាគារនៃក្រសួងមហាផ្ទៃ | សមាជិក |
| ៦- លោកស្រី | **សុន សុខាលីដា** | ប្រធាននាយកដ្ឋានកិច្ចការអយ្យការ និងកិច្ចការ អនុវត្តទោសនៃក្រសួងយុត្តិធម៌ | សមាជិក |
| ៧- លោក | **លី សុផាណា** | ព្រះរាជអាជ្ញានៃក្រសួងយុត្តិធម៌ | សមាជិក។ |

**ប្រការ២ ..**

**គ.ដ.ល.** ត្រូវអនុវត្តភារកិច្ចស្របតាមមាត្រា៥១៤ មាត្រា៥១៥ និងមាត្រា៥១៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ គោលការណ៍ណែនាំ ឬសេចក្តីណែនាំរបស់ក្រសួងយុត្តិធម៌ រួមនិងបទប្បញ្ញត្តិជាធរមានដែលមានការពាក់ព័ន្ធផ្សេងទៀត។

នៅក្នុងការអនុវត្តភារកិច្ចស្នូលរបស់ខ្លួនពាក់ព័ន្ធនឹងការផ្តល់យោបល់លើសំណើសុំដោះលែងដោយមានលក្ខខណ្ឌ, **គ.ដ.ល.** ត្រូវពិនិត្យដោយយកចិត្តទុកដាក់លើពាក្យសុំរបស់ទណ្ឌិត យោបល់របស់ព្រះរាជអាជ្ញា និងឯកសារនានាពាក់ព័ន្ធនឹងសំណើសុំដោះលែងដោយមានលក្ខខណ្ឌទាំងអស់ដែលទទួលបានពីប្រធានសាលាដំបូង និងដោយត្រូវពិនិត្យឱ្យបានម៉ត់ចត់លើលក្ខខណ្ឌមួយចំនួនដូចតទៅ៖

- ការកែប្រែគំនិតមារយាទល្អក្នុងរយៈពេលជាប់ឃុំ និងការមានសម្បទាដែលអាចបញ្ចូលខ្លួនទៅក្នុងសង្គមវិញរបស់ទណ្ឌិត ដូចមានចែងក្នុងមាត្រា៥១២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ
- ការបំពេញលក្ខខណ្ឌទាក់ទងនឹងថិរវេលានៃទោសដែលទណ្ឌិតបានអនុវត្តរួចរាល់ ដូចមានចែងក្នុងមាត្រា៥១៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ
- ស្ថានភាពនៃភាពចង្អៀតណែននៃពន្ធនាគារដែលទណ្ឌិតកំពុងអនុវត្តទោស
- លក្ខខណ្ឌចាំបាច់ផ្សេងទៀត ដែលអាចធានាដល់ការធ្វើសមាហរណកម្មទណ្ឌិតឱ្យចូលទៅរួមរស់នៅក្នុងសង្គមវិញ។

**ប្រការ៣ ..**

អនុប្រធាន និងសមាជិកនៃ **គ.ដ.ល.** ត្រូវចូលរួមកិច្ចប្រជុំតាមការអញ្ជើញរបស់ប្រធាន **គ.ដ.ល.** ។ ក្នុងករណីប្រធានអវត្តមានឬមានធុរៈ អនុប្រធានអាចកោះប្រជុំ និង/ឬ ដឹកនាំកិច្ចប្រជុំជំនួសបាន តាមការប្រគល់សិទ្ធិពីប្រធាន។

**គ.ដ.ល.** អាចអញ្ជើញតំណាងស្ថាប័នពាក់ព័ន្ធ, មន្ត្រីជំនាញ, អ្នកឯកទេស ឬផ្នែកឯកជនចូលរួមប្រជុំ ដើម្បីពិភាក្សា ឬពិគ្រោះយោបល់លើរាល់បញ្ហាទាំងឡាយដែលទាក់ទងនឹងការងាររបស់ **គ.ដ.ល.**។

**ប្រការ៤ ..**

**គ.ដ.ល.** ប្រើប្រាស់ទីស្តីការក្រសួងយុត្តិធម៌ សម្រាប់កិច្ចដំណើរការនៃការអនុវត្តការងាររបស់ខ្លួន និងអាចប្រើប្រាស់មន្ត្រីក្រោមឱវាទក្រសួង-ស្ថាប័នពាក់ព័ន្ធ ដើម្បីអនុវត្តភារកិច្ច។

**គ.ដ.ល.** មានសិទ្ធិប្រើប្រាស់ត្រា និងប្រើថវិការបស់ក្រសួងយុត្តិធម៌ ក្នុងការបំពេញការងាររបស់ខ្លួន។

**ប្រការ៥ ..**

**គ.ដ.ល.** មានលេខាធិការដ្ឋានមួយជាសេនាធិការផ្នែករដ្ឋបាលដែលមានសមាសភាពដូចខាងក្រោម៖

១- លោកស្រី **សុន សុខាលីដា** ប្រធាននាយកដ្ឋាន នៃក្រសួងយុត្តិធម៌ ប្រធាន
២- កញ្ញា **រាម នាវត្តី** ប្រធានការិយាល័យ នៃក្រសួងយុត្តិធម៌ អនុប្រធាន
៣- លោក **ឃាក ទិសាលរតនៈ** ប្រធានការិយាល័យ នៃក្រសួងយុត្តិធម៌ អនុប្រធាន
៤- លោក **ឌី មថិលា** ប្រធានការិយាល័យ នៃក្រសួងយុត្តិធម៌ សមាជិក
៥- លោក **ម៉ុន ពិសិដ្ឋ** អនុប្រធានការិយាល័យ នៃក្រសួងយុត្តិធម៌ សមាជិក
៦- លោក **ជា សុខរ័ត្ន** អនុប្រធានការិយាល័យ នៃក្រសួងយុត្តិធម៌ សមាជិក
៧- លោក **ហាំង ចាន់សុធីយ៉ា** មន្ត្រីគ្រប់គ្រងរដ្ឋបាល នៃក្រសួងយុត្តិធម៌ សមាជិក
៨- លោក **អៀម សំណាង** មន្ត្រីគ្រប់គ្រងរដ្ឋបាល នៃក្រសួងយុត្តិធម៌ សមាជិក
៩- លោក **ពុធ មករា** មន្ត្រីគ្រប់គ្រងរដ្ឋបាល នៃក្រសួងយុត្តិធម៌ សមាជិក។

លេខាធិការដ្ឋានរបស់ **គ.ដ.ល.** មានភារកិច្ចដូចតទៅ៖

- ទទួលបន្ទុកការងាររដ្ឋបាលទូទៅប្រចាំថ្ងៃរបស់ **គ.ដ.ល.**
- ធ្វើការទំនាក់ទំនងជាមួយសាលាដំបូង និងអយ្យការអមសាលាដំបូងរាជធានី-ខេត្ត លើការងារពាក់ព័ន្ធនឹងការដោះលែងដោយមានលក្ខខណ្ឌ
- ទទួលរបាយការណ៍សកម្មភាពរបស់សាលាដំបូង និងអយ្យការអមសាលាដំបូងរាជធានី-ខេត្ត អំពីការងារពាក់ព័ន្ធនឹងការដោះលែងដោយមានលក្ខខណ្ឌ
- រៀបចំ និងសម្របសម្រួលកម្មវិធីការងារ កិច្ចប្រជុំ បេសកកម្ម និងពិធីការផ្សេងៗ របស់ **គ.ដ.ល.**
- រៀបចំឯកសារ របាយការណ៍ និងកំណត់ហេតុនៃកិច្ចប្រជុំ និងកម្មវិធីផ្សេងៗ របស់ **គ.ដ.ល.**
- បូកសរុបរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំរបស់ **គ.ដ.ល.**
- និងអនុវត្តការងារផ្សេងទៀត តាមការប្រគល់ភារកិច្ចរបស់ **គ.ដ.ល.**។

**ប្រការ៦** ៈ

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្ដីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៧** ៈ

នាយកខុទ្ទកាល័យ អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋានកិច្ចការតុលាការ ប្រធានគ្រប់អង្គភាពក្រោមឱវាទក្រសួងយុត្តិធម៌ ប្រធានសាលាដំបូង និងព្រះរាជអាជ្ញានៃអយ្យការអមសាលាដំបូងរាជធានី-ខេត្ត ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តសេចក្ដីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ៦កើត ខែស្រាពណ៍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែសីហា ឆ្នាំ២០២១
**រដ្ឋមន្ត្រី**

**កើត រិទ្ធ**

**កន្លែងទទួល ៖**

- ក្រសួងមហាផ្ទៃ
- ដូចប្រការ៧
- ឯកសារ កាលប្បវត្តិ